CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៩ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ការបិទនៅទីក្រុងឡុងប៊ិចសម្រាប់ទិវារំឭកថ្ងៃចងចាំ

ទីក្រុងឡុងប៊ិច,រដ្ឋកាលីហ្វ័រញ៉ា - បន្ថែមពីលើការបិទជាស្តង់ដារនូវទីតាំងនិងសេវាកម្មផ្សេងៗរបស់ទីក្រុងឡុងប៊ិចសម្រាប់ថ្ងៃបុណ្យទានមួយចំនួន សេវាកម្មនិងធនធានរបស់ទីក្រុងបន្ថែមដែលត្រូវបានអនុម័តសម្រាប់ការឆ្លើយតបនឹងជម្ងឺ COVID-19 ក៏នឹងត្រូវបិទផងដែរនៅក្នុងការប្រារព្ធទិវារំឭកថ្ងៃចងចាំនៅថ្ងៃច័ន្ទទី ២៥ ខែឧសភាឆ្នាំ ២០២០។

**ការបិទនូវសេវាកម្មនិងធនធានឆ្លើយតបនឹងជម្ងឺ COVID-19 នៃទីក្រុងក្នុងថ្ងៃបុណ្យទាននៅចុងសប្តាហ៍៖**

- ទីតាំងធ្វើតេស្តទាំងអស់នៅឡុងប៊ិចសម្រាប់ជម្ងឺ COVID-19 រួមទាំងសាលារៀន Jordan Plus និងមន្ទីរពេទ្យ St. Mary នឹងត្រូវបិទនៅថ្ងៃច័ន្ទទី ២៥ ខែឧសភា។
- គ្លីនិកធ្វើរោគវិនិច្ឆ័យរហ័ស (RAC) នឹងត្រូវបិទនៅថ្ងៃច័ន្ទទី ២៥ ខែឧសភា។
- មជ្ឈមណ្ឌលព័ត៌មានរួម (សម្រាប់អ្នកសារព័ត៌មាន) និងបណ្តាញព័ត៌មានបន្ទាន់ (សម្រាប់សហគមន៍) នឹងបិទប្រតិបត្តិការនៅថ្ងៃសៅរ៍ទី ២៣ ខែឧសភានិងថ្ងៃអាទិត្យទី ២៤ ខែឧសភា។ ធនធានទាំងពីរនឹងដំណើរការនៅថ្ងៃច័ន្ទទី ២៥ ខែឧសភា។

**អគារនិងសេវាកម្មរបស់ទីក្រុងដែលមានខាងក្រោមនឹងគោរពតាមកាលវិភាគដូចខាងក្រោមនៅថ្ងៃច័ន្ទទី ២៥ ខែឧសភាឆ្នាំ ២០២០។ សាលាក្រុងនៅតែបិទទ្វារជាសាធារណៈរហូតដល់មានការជូនដំណឹងបន្ថែម។**

**បិទនៅថ្ងៃច័ន្ទទី ២៥ ខែឧសភា៖**

- សេវាកម្មថែទាំសត្វនិង spcaLA*
- មជ្ឈមណ្ឌលផ្លាស់ប្តូរអាជីព*
- មជ្ឈមណ្ឌលសម្រាប់គ្រួសារដែលធ្វើការ*
- សាលាក្រុង*
- គណៈកម្មការពលរដ្ឋសម្រាប់បណ្តឹងប៉ូលីស
- សេវាកម្មអនុវត្តក្រម
- មជ្ឈមណ្ឌលធម្មជាតិ El Dorado*
- ទីស្នាក់ការកណ្តាលនៃក្រសួងពន្លត់អគ្គីភ័យ ក្រុមបង្ការអគ្គិភ័យ សេវាកម្មគាំទ្រនិងប្រតិបត្តិការ រួមទាំងរដ្ឋបាលសុវត្ថិភាពខាងសមុទ្រ
- ក្រសួងសុខាភិបាលនិងមូលដ្ឋានសុខាភិបាល
- អាជ្ញាធរលំនៅដ្ឋាន
- បណ្ណាល័យ*
- មជ្ឈមណ្ឌលធនធានអ្នកជិតខាង*
- ការិយាល័យការងារ (The WorkPlace) មជ្ឈមណ្ឌលឱកាសយុវជននិងការិយាល័យរដ្ឋបាល Pacific Gateway*
- ការិយាល័យឧទ្យាននិងកន្លែងសួនសហគមន៍*
- ការបោសថ្នល់
- អាងហែលទឹក*
- ការទាញនិងលក់រថយន្តនិងយានថយន្តផ្សេងទៀតដែលម្ចាស់មិនមកបង់រំលួស់
- ក្រសួងទឹក (ភាពអាសន្ននៃទឹកឬលូ៖ 562.570.2390)

**បើកនៅថ្ងៃច័ន្ទទី ២៥ ខែឧសភាជាមួយប្រតិបត្តិការដែលបានកែប្រែ៖**

- ស្ថានីយ៍អគ្គីភ័យនិងស្ថានីយការពារជីវិត

- ឧទ្យាន El Dorado Regional* (សម្រាប់ការកំសាន្តសកម្មតែប៉ុណ្ណោះ។ មិនអនុញ្ញាតឱ្យមានការប្រមូលផ្តុំឬលេងកីឡាជាក្រុម)
- ការិយាល័យសំខាន់ខាងមុខស្ថានីយ៍ប៉ូលីស
- ការិយាល័យកំពង់ផែ (កំពង់ផែ Alamitos Bay, កំពង់ផែ Shoreline)*
- ការប្រមូលសំរាមនិងរបស់ដែលអាចកែច្នៃឡើងវិញ (ការិយាល័យនឹងត្រូវបិទប៉ុន្តែសំរាមនិងរបស់របរដែលអាចកែច្នៃឡើងវិញនឹងត្រូវប្រមូលដូចធម្មតា)
- ក្រុមបញ្ជូនសេវាកម្មហ្គាសបើក ២៤ ម៉ោង ៧ ថ្ងៃក្នុងមួយសប្តាហ៍សំរាប់ការទទួលទូរស័ព្ទបន្ទាន់នៅលេខ 562.570.2140

*សញ្ញានេះ (*) ចង្អុលបង្ហាញអំពីទីតាំងនិងសេវាកម្មទីក្រុងដែលកំពុងប្រតិបត្តិការក្រោមប្រតិបត្តិការដែលបានកែប្រែរហូតដល់មានការជូនដំណឹងបន្ថែមដែលជាលទ្ធផលនៃការកំរិតចម្ងាយផ្ទែករាងកាយនៃជម្ងឺ COVID-19។*

**សាលាក្រុង**

សាលាក្រុងបានបិទការចូលជាសាធារណៈនៅថ្ងៃទី ១៨ ខែមីនាហើយនឹងនៅតែបិទរហូតដល់មានការជូនដំណឹងបន្ថែម។ ប្រជាជនត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់សេវាកម្មតាមអ៊ិនធឺរណែតក្នុងអំឡុងពេលនេះ។

**ការបោសថ្នល់**

មិនមានការបោសថ្នល់ឬការអនុវត្តន៍តាមការបំពានច្បាប់បោសថ្នល់នៅថ្ងៃច័ន្ទទី ២៥ ខែឧសភាឡើយ។ ការបោសថ្នល់នឹងបន្តមានតាមកាលវិភាគធម្មតានៅថ្ងៃអង្គារទី ២៦ ខែឧសភា។

**ការអនុវត្តច្បាប់ចំណតរថយន្ត**

សូមមេត្តាអានម៉ែត្រចំណតរបស់លោកអ្នក៖ ម៉ែត្រចំណតនឹងនូវតែអនុវត្តនៅថ្ងៃច័ន្ទទី ២៥ ខែឧសភាលើកលែងតែម៉ែត្រនោះសរសេរថា "លើកលែងនៅថ្ងៃបុណ្យទាន (Exempt on Holidays)។" ថ្ងៃនិងម៉ោងនៃការអនុវត្តច្បាប់មានសរសេរនៅខាងក្នុងម៉ែត្រ។

**សំរាមនិងរបស់ដែលអាចកែច្នៃឡើងវិញ**

សំរាមនិងរបស់ដែលអាចកែច្នៃឡើងវិញនឹងត្រូវប្រមូលតាមការគ្រោងទុកដូចធម្មតានៅថ្ងៃច័ន្ទទី ២៥ ខែឧសភា។

**ការទាញនិងលក់រថយន្តនិងយានថយន្តផ្សេងៗដែលម្ចាស់មិនមកបង់រំលួស់**

កន្លែងប្រតិបត្តិការទាញនិងកន្លែងផ្ទុកយានយន្តដែលមានទីតាំងនៅ 3111 E. Willow St. ដែលស្ថិតនៅចន្លោះផ្លូវ Temple Avenue និងផ្លូវ Redondo Avenue នឹងត្រូវបិទនៅថ្ងៃច័ន្ទទី ២៥ ខែឧសភា។ ម៉ោងធ្វើការធម្មតាគឺ៖

- ថ្ងៃច័ន្ទដល់ថ្ងៃសុក្រម៉ោង ៨ ព្រឹកដល់ម៉ោង ៥ ល្ងាច។
- ថ្ងៃសៅរ៍ពីម៉ោង ៨ ព្រឹកដល់ម៉ោង ៤ ល្ងាច។
- បិទថ្ងៃអាទិត្យនិងថ្ងៃបុណ្យទាន។

យានយន្តនិងទ្រព្យសម្បត្តិអាចមកបង់រំលួស់បាននៅក្រៅម៉ោងដែលបានរៀបរាប់ខាងលើជាមួយនឹងថ្លៃសេវាបន្ថែម។ ព័ត៌មានបន្ថែមអាចរកបានតាមអ៊ីនធឺណិត។

**បណ្ណាល័យ**

បណ្ណាល័យសាធារណៈទាំងអស់នៅឡុងប៊ិចបានបិទជាសាធារណៈនៅថ្ងៃទី ១៨ ខែមីនាហើយនឹងបិទរហូតដល់មានការជូនដំណឹងបន្ថែម។ អ្នកដែលចូលប្រើបណ្ណាល័យត្រូវបានលើកទឹកចិត្តអោយប្រើប្រាស់ធនធានឌីជីថលយ៉ាងច្រើនរបស់បណ្ណាល័យឡុងប៊ិចរួមមានកាតាឡុកបណ្ណាល័យ ធនធានដែលអាចទាញយកពីអ៊ីនធឺណិត និងមូលដ្ឋានទិន្នន័យដែលអាចរកបាន ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្តា។ ខ្សែទូរស័ព្ទរបស់បណ្ណាល័យ (562.570.7500) ដែលជាធម្មតាអាចប្រើបានចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ៥ ល្ងាចពីថ្ងៃអង្គាររហូតដល់ថ្ងៃសៅរ៍នឹងត្រូវបិទនៅថ្ងៃសៅរ៍ទី ២៣ ខែឧសភាដើម្បីប្រារព្ធទិវារំឭកថ្ងៃចងចាំ។

ការសាកសួរសារព័ត៌មានអាចបញ្ជូនទៅកាន់មជ្ឈមណ្ឌលព័ត៌មានរួមតាមលេខ 562.570.6397 ឬផ្ញើអ៊ីមែលទៅ jic@longbeach.gov។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #